**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៣៦. អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/ ០៦០២ /១៥៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការ បង្កើតក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- យោងតាមសំណើរបស់សហប្រធានក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

**ស ម្រ ច**

**មាត្រា ១.-**

បង្កើតគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកពិនិត្យ និងអនុម័តពាក្យច្បាប់ ហៅកាត់ថា **"គណៈកម្មការបណ្ឌិតសភា"** ដែលមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| - ឯកឧត្តម | សំ សុខផល | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | ប្រធាន |
| - ឯកឧត្តមសាស្ត្រាចារ្យ បណ្ឌិត | ស៊ន សំណាង | ប្រធានរាជបណ្ឌិតសភាកម្ពុជា | អនុប្រធាន |
| -ឯកឧត្តមសាស្ត្រាចារ្យ បណ្ឌិត | ឆយ យីហ៊ាង | សមាជិករាជបណ្ឌិតសភាកម្ពុជា ប្រធានវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ នៃរាជបណ្ឌិតសភាកម្ពុជា | |

| | | | |
|---|---|---|---|
| -លោកសាស្ត្រាចារ្យ បណ្ឌិត | ច័ន្ទ សំណព្វ | ប្រធាននាយកដ្ឋាន នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ តំណាងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| - លោកសាស្ត្រាចារ្យ | សឹង ផុស | អនុប្រធាននាយកដ្ឋានអក្សរសាស្ត្រខ្មែរ នៃ វិទ្យាស្ថានភាសាបរទេស តំណាងវិទ្យាស្ថានភាសា-បរទេសកម្ពុជា | សមាជិក |
| - លោក | ប៊ុន ហុន | មេធាវី តំណាងគណៈមេធាវីកម្ពុជា | សមាជិក |
| - តំណាងក្រសួងពាក់ព័ន្ធ | | | សមាជិក |
| - ឯកឧត្តមសាស្ត្រាចារ្យ បណ្ឌិត | ហេង វង្សប៊ុនឆាត | ឧត្តមទីប្រឹក្សារាជរដ្ឋាភិបាល | ទីប្រឹក្សា |
| - ឯកឧត្តមសាស្ត្រាចារ្យ បណ្ឌិត | សុខ ស៊ីផាន់ណា | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ទីប្រឹក្សា |

ទីប្រឹក្សារបស់គណៈកម្មការបណ្ឌិតសភា ពុំមែនជាសមាជិករបស់គណៈកម្មការនេះទេ។ ទីប្រឹក្សាត្រូវបានអញ្ជើញឱ្យចូលរួមជាមួយគណៈកម្មការបណ្ឌិតសភាគ្រប់ពេល។ លោកអាចជូនមតិយោបល់បាន ប៉ុន្តែលោកពុំចូលរួមបោះឆ្នោតសម្តែងមតិក្នុងគណៈកម្មការឡើយ ។

ក្រសួងពាក់ព័ន្ធត្រូវចាត់បញ្ជូនតំណាង ទៅតាមសេចក្តីស្នើសុំរបស់គណៈកម្មការបណ្ឌិតសភា ។

## មាត្រា ២.-

គណៈកម្មាការបណ្ឌិតសភា មានភារកិច្ចពិនិត្យ និងអនុម័តពាក្យច្បាប់ដែលកំពុងប្រើប្រាស់ ពាក្យច្បាប់ថ្មី និងពាក្យច្បាប់ដែលបកប្រែពីភាសាបរទេស ។ នីតិវិធី នៃការពិនិត្យ និងអនុម័តពាក្យរបស់គណៈកម្មការបណ្ឌិតសភា ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងមួយ ដែលគណៈកម្មការអនុម័តខ្លួនឯង។

ពាក្យទាំងឡាយដែលគណៈកម្មការបណ្ឌិតសភាអនុម័តរួចហើយ ត្រូវចងក្រងជាសទ្ទានុក្រម និងត្រូវបញ្ជូនទៅប្រមុខរាជរដ្ឋាភិបាល ដើម្បីសុំការប្រកាសឱ្យប្រើនៅទូទាំងប្រទេស ។

## មាត្រា ៣.-

គណៈកម្មការបណ្ឌិតសភា មានលេខាធិការដ្ឋានមួយជាជំនួយការ ។

លេខាធិការដ្ឋានជាអង្គភាពបច្ចេកទេស ដែលជួយគណៈកម្មការក្នុងការងារព្រាងពាក្យ ការងាររដ្ឋបាល ការងារភស្តុភារ និងហិរញ្ញកិច្ច ព្រមទាំងការងារផ្សេងៗទៀត ពាក់ព័ន្ធនឹងគណៈកម្មការ ។

សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាននេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

## មាត្រា ៤.-

គណៈកម្មការបណ្ឌិតសភា ស្ថិតក្រោមការគ្រប់គ្រងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

គណៈកម្មការបណ្ឌិតសភា អាចទទួលជំនួយឧបត្ថម្ភពីសប្បុរសជន និងពីអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ។

មាត្រា ៥. –

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ព្រមទាំងមន្ត្រីដែលពាក់ព័ន្ធដទៃទៀត ត្រូវអនុវត្តអនុក្រឹត្យនេះ ។

មាត្រា ៦. –

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

"ដើម្បីសុំហត្ថលេខា"

សហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

ឌិត មុន្ទី សុខ អាន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នរដ្ឋ
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ